# *-RECOMMENDATIONS-*

## *National Conference on Persons in Street Situations*
## *15-16 December 2015, Phnom Penh, Cambodia*

**PREVENTION OF STREET SWEEPS:**

- Develop Standard Operating Codes of Conduct on persons in street situations for law enforcement officials involved in street sweeps, including a child-friendly version:
    - Need to clarify the role and jurisdiction of Khan's security forces
    - Regular training and refresher sessions required
    - Copy to be provided to affected groups, including entertainment workers
- Sensitize law enforcement officials on the legal framework involving street sweeps and persons in street situations, and other relevant laws, policies and documents such as the Explanatory note on the Law on Suppression of Human Trafficking and Sexual Exploitation.
- MoSAVY/DoSAVY, municipality and local authorities to inform community networks and NGOs in advance before major events take place, when and where these events requiring special security are planned, in order to inform affected groups and organize referrals.

**DURING STREET SWEEPS:**

- Zero tolerance for physical and verbal violence and abuse by law enforcement or other duty bearers, including sexual or gender-based harassment and discrimination.
- Zero tolerance for bribery (eg., money, work or sex in exchange for release)and extortion of money and/or goods such as mobile phones.
- Inform of legal basis for the arrest to affected groups and ensure right to legal advice.
- Identify better options for referral to services.
- Allow communication of affected individuals and groups with their family members and other support networks/ groups.
- Community networks, NGOs and UN to be informed of the arrests by MoSAVY/DoSAVY, municipality or local authorities.
- No family separation and ensure at all time that children are protected and are not left unattended or at any risk

**AT THE SOCIAL AFFAIRS/DROP-IN CENTER:**

**Minimum services**

- Respect for human rights to be ensured at all times.
- Immediate release of women who are pregnant, recently delivered, have children or need essential health services.
- Immediate release of children with parents/caregivers.
- Immediate release or at least priority and rapid handling of release requests especially for emergency cases and people with severe or chronic diseases who need access to regular treatment or care with the necessary confidentiality.
- Secure, at all-time, minimum standards of service packages, including safety, water and sanitation, , access to free and adequate food, health services and psychosocial support, with separate rooms, toilets and bathing facilities for women and children.
- Standardized registration process with demographic data collected and available to direct service providers, maintained under standards of confidentiality and privacy.
- Ensure communication with family and other support networks/ groups, including in-person visits from families and care givers.
- Case management of children, particularly the assessment of the situation of each child, development and implementation of a case plan.

**Management**

- Clarify objective of the center and its procedures: Drop in center for temporary period for vulnerable people on voluntary basis.
- Standard Operating Procedures for minimum standards and 'handling/supporting' people when referred to the Department of Social Affairs (temporary transit) and at social affairs centers including a prior- assessment/screening of their situation and needs for referral options.
- Review the structure of the center and its management, provided services and target groups.
- Ensure close coordination with Phnom Penh municipality health department and Pochentong health authorities under MOH for regular visit by medical team (weekly and when urgent issues arise).
- Unhindered access to UN and NGOs to the center.
- Establish child safeguarding procedures for the center and build the capacity of the center's staff.

## GENERAL RECOMMENDATIONS:

**General**

- Maintain regular contacts/meetings between MoSAVY/DoSAVY, local authorities, UN and NGOs, through the TWG and other meetings as necessary, for information sharing, problem solving purposes as well as short, medium and long term solutions
- Mobilize national budget and external resources.

**On street sweeps**

- Moratorium on street arrests to prioritize assessment and alternative options based on assessment to give them a chance to see how alternative options works.
- Seek written commitment (letter) from Phnom Penh Municipality on suspension of all street arrests to further fully inform to all necessary services.
- Continue Police-Community Partnership Initiative with already trained law enforcement officials and expand in locations when and where issues arise. This should include sensitization training on the needs of persons in street situations and experiences of violence to Khan's police and security guards.

**On alternative options and upgraded support and services**

- Conduct assessment on current services available and multi-sectoral needs of persons in street situations in consultation with affected groups.
- Define types of services to offer voluntary: continuum of services from minimum services to more specialized ones.
- Seek possibilities for family or community reintegration in partnership with NGOs.
- Identify other opportunities (services incentives/ volunteers?) such as recreational activities for education/vocational training as well as trust and self-confidence, knowing it takes time.
- Possibility of NGO service user card jointly issued by Government and NGOs (access free health services and link to facilitate families to get ID poor card).
- Develop Standard Operating Procedures to ensure more systematic cooperation with local authorities, direct/communes, Women and Children Committees (WCC), MOWA and NGOs for safe referral to adequate services.
- Awareness raising among affected groups, including entertainment workers, to understand the funding provided to WCC for women's issues.
- Continue strong collaboration with and funding for community support groups and NGOs who provide essential services (e.g., health, human rights, shelter, psychosocial support…) and explore opportunities to leverage funding and service through decentralization and deconcentration mechanism, including access to funding provided to communes/sangkats (eg. CCWC).
- Promote access to social protection mechanisms for the affected populations and their family members (including e.g., urban ID poor card, health equity fund, food support) and inform the concerned families on how it works for them to access services

- Align support services with university schools and programmes in social work, psychology, medicine, nursing, and law, to ultimately enable internship placements of university students in public service settings.
- Access to continuum of education/vocational training (at/through qualified voluntary social affairs centers or NGOs…) and livelihood opportunities to affected populations:
    - Education opportunities
    - Vocational training based on employment opportunities available
    - Financial literacy, access to microfinance
- Legal literacy for affected people to know the laws and support for legal services to report and seek justice.

**-<u>GROUP SPECIFIC RECOMMENDATIONS</u>-**

***CHILDREN LIVING / WORKING ON THE STREETS:***

- Social housing implemented by Government.
- Independent/group living supported/implemented by NGOs.
- Child-led "safe streets" (consultation, advocacy and funding) implemented by Government and NGOs.
- Life-skills/safety education supported/implemented by NGOs.
- Day care for street families supported/implemented by NGOs.
- Provide children living or working on the street with NGO service user cards that are recognized by police and authorities so that the relevant NGO can be contacted to refer the child for services and prevent unnecessary placement of children in Prey Speu or similar center.
- Case management by social workers (Government/NGO) to identify and implement a durable solution for the reintegration and safety of children living and/or working on the street.

***PERSONS WITH PSYCHOSOCIAL DISABILITIES:***

- Social support: day center, night shelter (full, free and informed consent).
- Creation of community-based mental health services and peer support group with linkages to medical services with progressively increasing government financial contributions.
- Review, implement and roll-out action plan for mental health.
- Mainstream psychosocial disability within the national disability legislation and related monitoring.
- Ensure that people with psychosocial disabilities are included in existing and new initiative and programmes under the Cambodian localization of the 2030 development agenda (goal 3: to promote mental health well-being.
- Promote awareness and more supportive behavior change on respect and the rights of people with psychosocial disabilities among the general public.
- Sensitization of authorities such as the police in managing persons with psychosocial disabilities on the streets.
- Sensitization of the peer group and identify focal persons amongst the peer groups to support persons with psychosocial disabilities (good practice from Kolkata, India).

***ENTERTAINMENT WORKERS:***

- Ensure full respect of the Laws and related explanatory notes and promote decriminalization of sex work.
- Support the Ministry of Labour and Vocational Training to roll out implementation and monitoring of Prakas 194 which sets occupational health & safety standards for entertainment worker places.
- Promote access to employment in entertainment places (to reduce street-based work) and other voluntary vocational training opportunities
- Empower community network to inform and support their members on legal framework and to work closely with local authorities and law enforcement officials.

-------------

*អនុសាសន៍* -

សន្និសីទថ្នាក់ជាតិស្តីពីជនដែលស្ថិតក្នុងស្ថានភាពនៅតាមចិញ្ចើមផ្លូវ

១៥-១៦ ខែធ្នូឆ្នាំ២០១៥ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

<u>ការបង្ការការប្រមូលមនុស្សពីតាមចិញ្ចើមផ្លូវ:</u>

- រៀបចំក្រមសីលធម៌ស្តង់ដាប្រតិបត្តិការ ស្តីពីស្តីពីជនស្ថិតក្នុងស្ថានភាពរស់នៅតាមចិញ្ចើមផ្លូវ សម្រាប់មន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធនឹងការប្រមូលមនុស្សពីតាមចិញ្ចើមផ្លូវ រួមទាំងឯកសារដែលងាយយល់សំរាប់កុមារ៖
    - ត្រូវពន្យល់ឲ្យច្បាស់ពីតួនាទីនិងដែនសមត្ថកិច្ចរបស់កម្លាំងសន្តិសុខខណ្ឌ
    - ត្រូវមានការបណ្តុះបណ្តាល និងវគ្គបំពាក់បំប៉នឲ្យបានទៀងទាត់តាមការចាំបាច់
    - ត្រូវផ្តល់ឯកសារថតចម្លងដល់ក្រុមដែលរងផលប៉ះពាល់រួមទាំងអ្នកបំរើសេវាកម្បាន្ត
- ផ្សព្វផ្សាយដល់មន្ត្រីអនុវត្តច្បាប់អំពីក្របខណ្ឌច្បាប់ដែលពាក់ព័ន្ធនឹងការប្រមូលមនុស្ស និងដល់ជនដែលរស់នៅតាមចិញ្ចើមផ្លូវ ព្រមទាំងអំពីច្បាប់ គោលនយោបាយ និងឯកសារដទៃទៀតដែលពាក់ព័ន្ធ មានដូចជាកំណត់ពន្យល់អំពីច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទជាដើម។
- ក្រសួង និងនាយកដ្ឋានសង្គមកិច្ច (MoSAVY/DoSAVY) សាលាក្រុងនិងអាជ្ញាធរមូលដ្ឋាន ត្រូវជូនដំណឹងដល់គ្រប់ជាបណ្តាញសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលឲ្យដឹងជាមុន មុនពេលព្រឹត្តិការណ៍សំខាន់ៗកើតមានឡើង អំពីពេលវេលា និងកន្លែងនៃព្រឹត្តិការណ៍ទាំងនេះ ដែលតម្រូវឲ្យមានផែនការសន្តិសុខពិសេស ដើម្បីឲ្យក្រុមដែលរងផលប៉ះពាល់បានដឹង និងរៀបចំសម្រាប់ការបញ្ជូនពួកគាត់ទៅកាន់ទីតាំងផ្សេង។

**<u>នៅក្នុងអំឡុងពេលប្រមូលមនុស្សពីតាមចិញ្ចើមផ្លូវ៖</u>**

- មិនអត់ឱនជាដាច់ខាតចំពោះអំពើហឹង្សា និងការរំលោភបំពានលើរាងកាយ និងពាក្យសំដីដោយមន្ត្រីអនុវត្តច្បាប់ ឬអាជ្ញាធរផ្សេងៗ រាប់ទាំងការយាយី និងការរើសអើងភេទ ឬយេនឌ័រ៖
- មិនអត់ឱនជាដាច់ខាតចំពោះការសូកប៉ាន់(មានជាដូចជា លុយកាក់ ការធ្វើការងារ ឬការដោះដូរផ្លូវភេទជា ថ្នូរនឹងការដោះលែង) និងជំរិតទារប្រាក់ និង/ឬ សម្ភារៈដូចជាទូរស័ព្ទដៃជាដើម។
- ប្រាប់ឲ្យដឹងអំពីមូលដ្ឋានច្បាប់សម្រាប់ការចាប់ខ្លួនដល់ក្រុមដែលរងផលប៉ះពាល់ និងធានាសិទ្ធិទទួលបាន ការណែនាំផ្នែកច្បាប់។
- កំណត់ជម្រើសដែលល្អប្រសើរសម្រាប់ការបញ្ជូនទៅសេវាកម្មផ្សេងៗ។
- អនុញ្ញាតឲ្យបុគ្គល និងក្រុមដែលរងផលប៉ះពាល់អាចប្រាស្រ័យទាក់ទងជាមួយសមាជិកគ្រួសាររបស់ពួកគេ និង បណ្តាញ/ក្រុមគាំទ្រដទៃផ្សេងទៀត។
- ត្រូវផ្តល់ព័ត៌មានដល់បណ្តាញសហគមន៍ អង្គការមិនមែនរដ្ឋាភិបាលនានា និងអង្គការសហប្រជាជាតិ ដឹងអំពីការចាប់ប្រមូលដោយក្រសួង និងនាយកដ្ឋានសង្គមកិច្ច (MoSAVY/DoSAVY)សាលាក្រុង ឬអាជ្ញាធរមូលដ្ឋាន។
- គ្មានការបំបែកសមាជិកក្រុមគ្រួសារ ហើយគ្រប់ពេលវេលា ត្រូវធានាថា កុមារគ្រប់រូបទទួលបានការការពារនិងមិនត្រូវទុកចោលដោយគ្មានការថែមទាំ ឬស្ថិតក្នុងហានិភ័យណាមួយឡើយ។

**<u>នៅមជ្ឈមណ្ឌលសង្គមកិច្ច /មជ្ឈមណ្ឌលសំចត</u>**

**<u>សេវាអប្បបរមា</u>**

- ការគោរពសិទ្ធិមនុស្សត្រូវតែធានាឲ្យមានគ្រប់ពេលវេលា។
- ត្រូវដោះលែងជាបន្ទាន់ចំពោះស្ត្រីដែលមានផ្ទៃពោះ ស្ត្រីដែលទើបសម្រាលកូន ស្ត្រីដែលមាននកូនតូចៗ ឬដែលត្រូវការសេវាសុខភាពចាំបាច់។
- ត្រូវដោះលែងជាបន្ទាន់កុមារដែលមានឪពុកម្តាយ ឬអ្នកថែទាំ។
- ត្រូវដោះលែងជាបន្ទាន់ ឬជាអទិភាពបំផុត ហើយត្រូវចាត់ការសំណើរសុំការដោះលែងឲ្យបានឆាប់រហ័ស ជាពិសេសសម្រាប់ករណីបន្ទាន់បង្ខំ និងអ្នកដែលមានជំងឺធ្ងន់ធ្ងរឬរ៉ាំរ៉ៃដែលត្រូវការការព្យាបាល ឬការថែទាំសុខភាព ទៀងទាត់ ដោយត្រូវរក្សាការសម្ងាត់ចាំបាច់។
- គ្រប់ពេល ត្រូវធានាដល់ស្តង់ដារអប្បបរមានៃកញ្ចប់សេវារួមបញ្ចូលទាំង សុវត្ថិភាព ទឹក និងអនាម័យ ការទទួលបានអាហារគ្រប់គ្រាន់ និងដោយឥតគិតថ្លៃ សេវាសុខភាព និងការគាំទ្រផ្នែកផ្លូវចិត្ត ដោយមានបន្ទប់ដាច់ដោយឡែក បង្គន់ សម្ភារៈងូតទឹកសម្រាប់ស្ត្រីនិងកុមារ។
- ត្រូវមានដំណើរការចុះឈ្មោះប្រកបដោយស្តង់ដាជាមួយនឹងទិន្នន័យប្រជាសាស្ត្រដែលប្រមូលបាន និងដែលមាន ដើម្បីតម្រង់ទិសដល់អ្នកផ្តល់សេវា ត្រូវរក្សាទុកក្រោមស្តង់ដារនៃការរក្សាការសម្ងាត់ និងភាពឯកជន
- ធានាឲ្យមានការប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារនិងបណ្តាញ ឬក្រុមគាំទ្រដទៃផ្សេងទៀត រាប់បញ្ចូលទាំង ការជួបសួរសុខទុកដោយផ្ទាល់ពីក្រុមគ្រួសារ និងអ្នកថែទាំ។
- ការគ្រប់គ្រងករណីរបស់កុមារ ជាពិសេសការវាយតម្លៃអំពីស្ថានភាពរបស់កុមារម្នាក់ៗ ការបង្កើត និងការអនុវត្តផែនការករណីមួយៗ។

**<u>ការគ្រប់គ្រង</u>**

- ពន្យល់បំភ្លឺអំពីគោលដៅរបស់មជ្ឈមណ្ឌល និងនីតិវិធីរបស់មជ្ឈមណ្ឌលៈ មជ្ឈមណ្ឌលសំចតសម្រាប់រយៈពេល ស្នាក់នៅបណ្តោះអាសន្នសំរាប់ជនដែលងាយរងគ្រោះ ដោយផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត។
- នីតិវិធីប្រតិបត្តិការស្តង់ដាសម្រាប់បទដ្ឋានអប្បបរមា និង"ការគ្រប់គ្រង ឬការគាំទ្រ" ជនទាំងឡាយ នៅពេលដែលបញ្ជូនពួកគាត់ទៅមន្ទីរសង្គមកិច្ច (កន្លែងទទួលបណ្តោះអាសន្ន) និងនៅមជ្ឈមណ្ឌលសង្គមកិច្ច រួមទាំងការសម្ភាសន៍ ឬការវាយតម្លៃជាមុន អំពីស្ថានភាពរបស់ពួកគេ និងតម្រូវការសម្រាប់ជម្រើសនៃការបញ្ជូន។
- ពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធនៃមជ្ឈមណ្ឌល និងការគ្រប់គ្រងមជ្ឈមណ្ឌល សេវាដែលបានផ្តល់និងក្រុមគោលដៅ។
- ធានាឲ្យមានការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយមន្ទីរសុខាភិបាលរាជធានីភ្នំពេញនិងអាជ្ញាធរសុខភាពពោធិ៍ចិនតុងដែលស្ថិតក្រោមក្រសួងសុខាភិបាល ដើម្បីឲ្យមានការចុះពិនិត្យជាទៀងទាត់ពីក្រុមគ្រូពេទ្យ (រៀងរាល់ សប្តាហ៍និងនៅពេលមានបញ្ហាបន្ទាន់កើតមានឡើង)។
- អនុញ្ញាតឲ្យអង្គការសហប្រជាជាតិនិងអង្គការក្រៅរដ្ឋាភិបាលនានា ចូលក្នុងមជ្ឈមណ្ឌលនេះ ដោយគ្មានឧបសគ្គ។

- បង្កើតនីតិវិធីធានាការពារកុមារ សម្រាប់មជ្ឈមណ្ឌល និងពង្រឹងសមត្ថភាពដល់បុគ្គលិករបស់មជ្ឈមណ្ឌល។

**អនុសាសន៍ទូទៅ៖**

**ទូទៅ**

- រក្សាទំនាក់ទំនងឬកិច្ចប្រជុំឲ្យបានទៀងទាត់រវាងក្រសួង ឬមន្ទីរសង្គមកិច្ច អាជ្ញាធរមូលដ្ឋាន អង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា តាមរយៈក្រុមការងារបច្ចេកទេស និងកិច្ចប្រជុំដទៃទៀតតាមការចាំបាច់ ដើម្បីចែករំលែកព័ត៌មាន គោលបំណងដោះស្រាយបញ្ហា ក៏ដូចជា ការស្វែងរកដំណោះស្រាយ រយៈពេលខ្លី មធ្យម និងយូរអង្វែង។
- រៃអង្គាសប្រភពធនធានថវិកាជាតិនិងប្រភពធនធានផ្សេងៗពីខាងក្រៅ។

**អំពីការប្រមូលមនុស្សពីតាមចិញ្ចើមផ្លូវ៖**

- ផ្អាកជាបណ្តោះអាសន្ន រាល់សកម្មភាពចាប់ប្រមូលមនុស្សពីតាមចិញ្ចើមផ្លូវ ដើម្បីកំណត់អាទិភាពលើការវាយតម្លៃ និងជម្រើសផ្សេងពីនេះ ដោយផ្អែកលើការវាយតម្លៃ ដើម្បីផ្តល់ឱកាសឲ្យពួកគេ ពិនិត្យមើលថាតើជម្រើសផ្សេងពីនេះ មានប្រសិទ្ធភាពកម្រិតណា។
- ស្វែងរកការសន្យាជាលាយលក្ខខណ្ឌអក្សរ (លិខិតស្នាម) ពីសាលារាជធានីភ្នំពេញស្តីពីការផ្អាកការចាប់ប្រមូល មនុស្សពីតាមចិញ្ចើមផ្លូវទាំងអស់ដើម្បីជូនដំណឹងឲ្យបានពេញលេញបន្ថែមទៀត អំពីរាល់សេវាចាំបាច់ទាំងអស់។
- បន្តអនុវត្តការផ្តួចផ្តើមភាពជាដៃគូរវាងនគរបាលនិងសហគមន៍ជាមួយមន្ត្រីអនុវត្តច្បាប់ដែលបានទទួលការបណ្តុះបណ្តាលរួចនិងពង្រីកនៅក្នុងតំបន់ផ្សេងៗ នៅពេលនិងនៅកន្លែងដែលមានបញ្ហាទាំងនេះកើតឡើង។ ការងារនេះ គួរតែរួមបញ្ចូល ការបណ្តុះបណ្តាលផ្សព្វផ្សាយអំពីសេចក្តីត្រូវការរបស់ជនដែលស្ថិតក្នុងស្ថានភាពរស់នៅតាមចិញ្ចើមផ្លូវ និងបទពិសោធន៍នៃអំពើហិង្សាពីសំណាក់កងសន្តិសុខ និងនគរបាលខណ្ឌ។

**អំពីជម្រើសផ្សេងៗនិងការគាំទ្រនិងសេវាដែលត្រូវបានធ្វើឲ្យប្រសើរឡើង**

- ធ្វើការវាយតម្លៃអំពីសេវាបច្ចុប្បន្នដែលមានស្រាប់ និងតម្រូវការពហុវិស័យនៃជនដែលស្ថិតក្នុងស្ថានភាពរស់នៅតាមចិញ្ចើមផ្លូវដោយមានការពិគ្រោះយោបល់ជាមួយក្រុមរងផលប៉ះពាល់។
- កំណត់ប្រភេទសេវា ដែលត្រូវផ្តល់តាមគោលការណ៍ស្ម័គ្រចិត្តៈការបន្តផ្តល់សេវាពីសេវាអប្បរមាដល់សេវាដែលមានលក្ខណៈឯកទេសច្រើនជាង។
- ស្វែងរកលទ្ធភាពសំរាប់ធ្វើសមាហរណកម្មក្រុមគ្រួសារឬសហគមន៍ក្នុងភាពជាដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាលនានា។
- កំណត់កាលានុវត្តភាពផ្សេងទៀត (ការលើកទឹកចិត្តផ្នែកសេវា ឬអ្នកស្ម័គ្រចិត្ត?) ដូចជាសកម្មភាពលំហែរកម្សាន្តសម្រាប់ការអប់រំ ឬការបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ដូចជា ការជឿទុកចិត្តនិងការជឿជាក់លើខ្លួនឯងដោយដឹងថា វាត្រូវការពេលវេលា។

- លទ្ធភាពមានប័ណ្ណអ្នកប្រើប្រាស់សេវាអង្គការមិនមែនរដ្ឋាភិបាល ដែលចេញរួមគ្នាដោយរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល (សិទ្ធិប្រើប្រាស់សេវាសុខភាពដោយឥតគិតថ្លៃ និងការទំនាក់ទំនងដើម្បីជួយសម្រួលដល់ក្រុមគ្រួសាររបស់ពួកគេទទួលបានប័ណ្ណសម្គាល់អ្នកក្រីក្រ)។
- បង្កើតនីតិវិធីស្តង់ដាប្រតិបត្តិការដើម្បីធានាឲ្យមានកិច្ចសហប្រតិបត្តិការកាន់តែមានលក្ខណៈជាប្រព័ន្ធជាមួយអាជ្ញាធរមូលដ្ឋានដោយផ្ទាល់ ជាមួយឃុំ/សង្កាត់ ក្រុមប្រឹក្សាស្ត្រីនិងកុមារ (WCC) ក្រសួងកិច្ចការនារី និងអង្គការមិនមែនរដ្ឋាភិបាលសម្រាប់ការបញ្ជូនប្រកបដោយសុវត្ថិភាព ទៅកាន់សេវាគ្រប់គ្រាន់។
- បង្កើនការយល់ដឹងក្នុងចំណោមក្រុមដែលរងផលប៉ះពាល់ រួមទាំងអ្នកបំរើសេវាកំសាន្តឲ្យយល់ដឹងអំពីមូលនិធិដែលបានផ្តល់ទៅឲ្យក្រុមប្រឹក្សាស្ត្រីនិងកុមារ(WCC) សម្រាប់បញ្ហាស្ត្រី។
- បន្តកិច្ចសហការរឹងមាំជាមួយ និងការផ្តល់ថវិកាសម្រាប់ក្រុមគាំទ្រសហគមន៍និងអង្គការមិនមែនរដ្ឋាភិបាលនានាដែលផ្តល់សេវាចាំបាច់ (មានជាអាទិ សេវាសុខភាព សេវាសិទ្ធិមនុស្ស សេវាទីជំរក សេវាគាំពារផ្លូវចិត្តជាដើម ។ល។) និងស្វែងរកកាលានុវត្តភាពដើម្បីពង្រីកការផ្តល់មូលនិធិនិងសេវាតាមរយៈវិមជ្ឈការនិងយន្តការវិសហមជ្ឈការ រួមទាំងសិទ្ធិទទួលការផ្តល់មូលនិធិដែលផ្តល់ឲ្យឃុំសង្កាត់(ឧទា. អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CCWC)។

- លើកកម្ពស់ការប្រើប្រាស់យន្តការគាំពារសង្គមសម្រាប់ជនដែលរងផលប៉ះពាល់ និងសមាជិកគ្រួសាររបស់ពួកគេ (រួមទាំង ជាអាទិ ប័ណ្ណអ្នកក្រីក្រនៅតាមជនបទ មូលនិធិសមភាពសុខភាពការគាំទ្រផ្នែកស្បៀងអាហារ (និងជូនដំណឹងដល់ក្រុមគ្រួសារពាក់ព័ន្ធអំពីថាតើប័ណ្ណនេះមានប្រយោជន៍យ៉ាងដូចម្តេចចំពោះពួកគេក្នុងការប្រើប្រាស់សេវាទាំងនេះ។

- ត្រូវធ្វើឲ្យសេវាគាំទ្រស៊ីគ្នាជាមួយនឹងសកលវិទ្យាល័យ និងកម្មវិធីនានាខាងផ្នែកការងារសង្គម ចិត្តវិជ្ជា ថ្នាំពេទ្យ ការថែទាំព្យាបាល និងច្បាប់ ដើម្បីផ្តល់លទ្ធភាពដល់ការដាក់បញ្ចូលកម្មវិធីកម្មសិក្សារបស់និសិត្សក្នុងការកំណត់សេវាសាធារណៈ

- សិទ្ធិទទួលបានការបន្តអប់រំ ឬការបណ្តុះបណ្តាលវិជ្ជាជីវៈ (នៅ ឬតាមរយៈមជ្ឈមណ្ឌលសង្គមកិច្ចការស្ម័គ្រចិត្តដ៏មានគុណភាព ឬអង្គការមិនមែនរដ្ឋាភិបាល... )និងកាលានុវត្តភាពក្នុងការចិញ្ចឹមជីវិតដល់ជនដែលរងផលប៉ះពាល់៖
    - កាលានុវត្តភាពអប់រំ
    - ការបណ្តុះបណ្តាលវិជ្ជាជីវៈផ្អែកលើកាលានុវត្តភាពការងារដែលមានស្រាប់
    - អក្ខរកម្មខាងហិរញ្ញវត្ថុ ការទទួលបានមីក្រូហិរញ្ញវត្ថុ
- អក្ខរកម្មផ្នែកច្បាប់សម្រាប់ជនដែលរងផលប៉ះពាល់ ដើម្បីយល់ដឹងពីច្បាប់និងគាំទ្រដល់សេវាកម្មច្បាប់ដើម្បីរាយការណ៍និងស្វែងយុត្តិធម៌។

**-<u>អនុសាសន៍ជាក់លាក់របស់ក្រុម</u>**

***កុមាររស់នៅ ឬធ្វើការនៅតាមចិញ្ចើមផ្លូវ៖***

- លំនៅដ្ឋានសង្គមត្រូវបានអនុវត្តដោយរដ្ឋាភិបាល។
- ការរស់នៅដោយឯករាជ្យឬជាក្រុម ត្រូវបានគាំទ្រ/អនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាលនានា។

- "សុវត្ថិភាពរស់នៅតាមផ្លូវ" ដែលដឹកនាំកុមារ(ការពិគ្រោះយោបល់ ការតស៊ូមតិ និងការផ្តល់មូលនិធិ)
-
- ការអប់រំអំពីបំណិនជីវិត/សុវត្ថិភាព ត្រូវបានគាំទ្រ/អនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាល។
- កិច្ចគាំពារប្រចាំថ្ងៃសម្រាប់គ្រួសារដែលនៅតាមចិញ្ចើមផ្លូវ ត្រូវបានគាំទ្រ/អនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាល។
- ផ្តល់ប័ណ្ណអ្នកប្រើប្រាស់សេវាអង្គការមិនមែនរដ្ឋាភិបាល ដល់កុមារដែលរស់នៅឬធ្វើការនៅតាមចិញ្ចើមផ្លូវ ដែលប័ណ្ណនេះត្រូវបានទទួលស្គាល់ដោយនគរបាលនិងអាជ្ញាធរ ដើម្បីអាចទំនាក់ទំនងទៅអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ ដើម្បីបញ្ជូនកុមារដើម្បីទទួលបាននូវសេវាផ្សេងៗ និងបង្ការការដាក់កុមារនៅមជ្ឈមណ្ឌលព្រៃស្ពឺឬមជ្ឈមណ្ឌលស្រដៀងគ្នា។
- ការគ្រប់គ្រងករណីដោយបុគ្គលិកសង្គមកិច្ច (រដ្ឋាភិបាល/អង្គការមិនមែនរដ្ឋាភិបាល) ដើម្បីកំណត់និងអនុវត្តដំណោះស្រាយមួយដែលលក្ខណៈយូរអង្វែងសម្រាប់ធ្វើសមាហរណកម្មនិងសុវត្ថិភាពរបស់កុមាររស់នៅនិង/ឬការធ្វើការងារនៅតាមចិញ្ចើមផ្លូវ។

*ជនដែលមានពិការភាពផ្នែកចិត្តសង្គម៖*:

- ការគាំទ្រផ្នែកសង្គម៖ មជ្ឈមណ្ឌលថែទាំប្រចាំថ្ងៃជំរកពេលយប់ (ការយល់ព្រមដោយសេរី ក្រោយពីបានទទួលព័ត៌មានគ្រប់គ្រាន់ពេញលេញ)។
- បង្កើតសេវាសុខភាពផ្លូវចិត្តនៅតាមសហគមន៍និងក្រុមមិត្តជួយមិត្ត ដោយភ្ជាប់ទៅនឹងសេវាពេទ្យ ជាមួយនឹងការកើនឡើងជាបណ្តើរៗនូវវិភាគទានផ្នែកហិរញ្ញវត្ថុរបស់រដ្ឋាភិបាល។
- ពិនិត្យឡើងវិញ អនុវត្ត និងដាក់ចេញជាផែនការសកម្មភាពសម្រាប់សុខភាពផ្លូវចិត្ត។
- បញ្ច្រៀបបញ្ហាពិការភាពចិត្តសង្គមនៅក្នុងច្បាប់ជាតិស្តីជនពិការនិងការត្រួតពិនិត្យដែលពាក់ព័ន្ធ។
- ធានាថាជនពិការផ្លូវចិត្តសង្គម ត្រូវបានរួមបញ្ចូលនៅក្នុងកម្មវិធី និងគំនិតផ្តួចផ្តើមថ្មីដែលមានស្រាប់ ដែលស្ថិតក្រោមឋានបរិច្ឆេទនៃរបៀបវារៈអភិវឌ្ឍឆ្នាំ២០៣០ (គោលដៅទី៣៖ដើម្បីលើកកម្ពស់សុខភាពផ្លូវចិត្ត។
- លើកកម្ពស់ការយល់ដឹងនិងការផ្លាស់ប្តូរឥរិយាបទគាំទ្របន្ថែមទៀតលើការគោរព និងសិទ្ធិរបស់ជនពិការផ្លូវចិត្តសង្គមក្នុងចំណោមសាធារណជនទូទៅ។
- បង្កើនការយល់ដឹងរបស់អាជ្ញាធរផ្សេងៗ ដូចជានគរបាលក្នុងការគ្រប់គ្រងជនពិការផ្លូវចិត្តសង្គមនៅតាមចិញ្ចើមផ្លូវ។

- បង្កើនការយល់ដឹងរបស់ក្រុមមិត្តអប់រំមិត្ត និងកំណត់ជនបង្គោលក្នុងចំណោមក្រុមមិត្តអប់រំមិត្តដើម្បីគាំទ្រដល់ជនពិការផ្លូវចិត្តសង្គម (ការអនុវត្តន៍ល្អពីកុលកាតាប្រទេសឥណ្ឌា។(

***បុគ្គលិកសេវាកំសាន្ត៖***

- ធានាការគោរពច្បាប់ឲ្យបានពេញលេញនិងកំណត់ពន្យល់ពាក់ព័ន្ធនានា និងលើកកម្ពស់ការលុបចោល បទព្រហ្មទណ្ឌចំពោះការងាររកស៊ីផ្លូវភេទ។

- គាំទ្រក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីដាក់ចេញនូវការអនុវត្តន៍និងការត្រួតពិនិត្យប្រកាស លេខ ១៩៤ ដែលកំណត់ស្តង់ដារសុខភាព និងសុវត្ថិភាពការងារសម្រាប់កន្លែងអ្នកបំរើសេវាកំសាន្ត។
- លើកកម្ពស់សិទ្ធិទទួលបានការងារនៅកន្លែងសេវាកំសាន្ត (ដើម្បីកាត់បន្ថយការងារនៅតាមចិញ្ចើមផ្លូវ)និងកាលានុវត្តភាពបណ្តុះបណ្តាលវិជ្ជាជីវៈដោយស្ម័គ្រចិត្តដទៃទៀតទៀត។
- ផ្តល់សិទ្ធិអំណាចឲ្យបណ្តាញសហគមន៍ដើម្បីជូនដំណឹងនិងគាំទ្រដល់សមាជិករបស់ខ្លួនស្តីពីក្របខ័ណ្ឌច្បាប់ និងធ្វើការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាននិងមន្ត្រីអនុវត្តច្បាប់។

-------------